# សូមជូនដំណឹងអំពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់ជនបរទេស។

ការចាក់ថ្នាំបង្ការ គឺជាមធ្យោបាយដ៏សំខាន់បំផុត ដើម្បីការពាររោគសញ្ញាធ្ងន់ធ្ងរ និងការស្លាប់។
សូមចូលរួមចាក់វ៉ាក់សាំង ដើម្បីសុខភាពអ្នក និងក្រុមគ្រួសារ។

## អ្នកត្រូវចាក់វ៉ាក់សាំង

① កុមារ(**អាយុពី៥-១១ឆ្នាំ): ការចាក់វ៉ាក់សាំងដូសទី១.២**

② ក្មេងជំទង់(**អាយុពី១២-១៧ឆ្នាំ): ការចាក់វ៉ាក់សាំងដូសទី១~៣**

③ មនុស្សពេញវ័យ(**អាយុពី១៨ឆ្នាំឡើងទៅ): ការចាក់វ៉ាក់សាំងដូសទី១~៤ ***

* ការចាក់វ៉ាក់សាំងដូសទី៤ គឺសម្រាប់អ្នកដែលមានអាយុចាប់ពី៥០ឆ្នាំឡើងទៅ ឬអាយុចាប់ពី១៨ឆ្នាំឡើងទៅ ដែលបានបញ្ចប់ការចាក់វ៉ាក់សាំងដូសទី៣ ដូចជាអ្នកដែលមានជំងឺប្រចាំកាយ, អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ និងអ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យ · ស្នាក់នៅ · បុគ្គលិក នៅមណ្ឌលដែលងាយនឹងឆ្លងមេរោគ

## ចន្លោះពេលចាក់វ៉ាក់សាំង

① **ការចាក់វ៉ាក់សាំងដូសទី១.២**

- វ៉ាក់សាំងPfizerសម្រាប់កុមារ, Pfizer, Moderna**៨សប្តាហ៍**
- វ៉ាក់សាំងNovavax **៣សប្តាហ៍**

② **ការចាក់វ៉ាក់សាំងដូសទី៣: ក្រោយ៣ខែ**បន្ទាប់ពីចាក់ដូសទី២

* វ៉ាក់សាំងJanssen គឺក្រោយ២ខែ បន្ទាប់ពីការចាក់ដូសទី១

③ **ការចាក់វ៉ាក់សាំងដូសទី៤: ក្រោយ៤ខែ** បន្ទាប់ពីចាក់ដូសទី៣

* វ៉ាក់សាំងJanssen គឺក្រោយ៤ខែ បន្ទាប់ពីការចាក់ដូសទី២

## ប្រភេទវ៉ាក់សាំង

① អាយុពី៥-១១ ឆ្នាំ : **វ៉ាក់សាំងPfizer សម្រាប់កុមារ**

② អាយុពី១២~១៧ ឆ្នាំ : **វ៉ាក់សាំងPfizer**

③ អាយុពី១៨ឆ្នាំឡើងទៅ : **វ៉ាក់សាំងPfizer, Moderna*, Janssen**, Novavax**

* វ៉ាក់សាំងModerna គឺណែនាំឱ្យចាក់សម្រាប់អាយុ៣០ឆ្នាំឡើងទៅ

** វ៉ាក់សាំងJanssenអាចចាក់ សម្រាប់តែក្នុងករណីពិសេសប៉ុណ្ណោះ

## វិធីសាស្រ្តចាក់វ៉ាក់សាំង

① **ជនដែលបានចុះឈ្មោះជាជនបរទេស:** អាចធ្វើការកក់ទុកតាមរយៈអនឡាញ ឬទូរស័ព្ទ និងចាក់ភ្លាមៗនៅថ្ងៃដែលចង់ចាក់

② **ជនដែលមិនបានចុះឈ្មោះជាជនបរទេស(ជនខុសច្បាប់) :** អាចធ្វើការកក់ទុកតាមទូរស័ព្ទ បន្ទាប់ពីចេញលេខគ្រប់គ្រងបណ្តោះអាសន្ន នៅមណ្ឌលសុខភាពសាធារណៈ ឬទៅកក់ផ្ទាល់នៅស្ថាប័នសម្រាប់ចាក់វ៉ាក់សាំង

③ **ជនបរទេសដែលបានបញ្ចប់ការចាក់វ៉ាក់សាំងមូលដ្ឋាននៅបរទេស :** អ្នកអាចធ្វើការកក់ទុក បន្ទាប់ពីចុះឈ្មោះប្រវត្តិនៃការចាក់វ៉ាក់សាំងនៅបរទេស នៅមណ្ឌលសុខភាពសាធារណៈ

## ※ សេចក្តីជូនដំណឹងផ្សេងទៀត

○ **ករណីកុមារ·ក្មេងវ័យជំទង់** ដើម្បីសុវត្ថិភាព និងត្រួតពិនិត្យនៃការចាក់វ៉ាក់សាំង **ចាំបាច់ត្រូវអមដំណើរជាមួយអាណាព្យាបាល ឬអ្នកតំណាងផ្លូវច្បាប់។**

○ គេហទំព័រកក់តាមរយៈអនឡាញ: https://ncvr.kdca.go.kr

○ ការទូរស័ព្ទ ទៅកក់ទុក: កក់ទុកតាមរយៈ ការទូរស័ព្ទទៅមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺកូរ៉េ (☏១៣៣៩) ឬមជ្ឈមណ្ឌលរដ្ឋាភិបាលក្នុងតំបន់

○ ការចាក់ដោយមិនកក់ទុកមុន: ការចាក់ភ្លាមៗ បន្ទាប់ពីចុះឈ្មោះក្នុងបញ្ជីបឋមនៃស្ថាប័នវេជ្ជសាស្រ្ត(បញ្ជាក់ដោយខ្សែទូរស័ព្ទ)